

# សិក្ខាសាលាស្តីពី
# “ បុព្វហេតុ សមិទ្ធផល និងទស្សនវិស័យនៃការងារកែទម្រង់ របស់រាជរដ្ឋាភិបាលកម្ពុជា ”

**ថ្ងៃព្រហស្បតិ៍ ៩ រោច ខែជេស្ឋ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៨**
**រាជធានីភ្នំពេញ៖ សណ្ឋាគារ សុខា**

## បទបង្ហាញស្តីពី
## កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

# មាតិកា

- សេចក្តីផ្តើម
- បុព្វហេតុនៃការធ្វើវិមជ្ឈការ
- កិច្ចដំណើរការនៃកំណែទម្រង់វិមជ្ឈការ
- សមិទ្ធផលនៃកំណែទម្រង់វិមជ្ឈការ
- ទិសដៅនៃកំណែទម្រង់វិមជ្ឈការ
- សន្និដ្ឋាន

# ១. សេចក្ដីផ្ដើម



- សន្តិភាព
- ស្ថេរភាពនយោបាយ
- ការឯកភាពជាតិ
- ការឯកភាពទឹកដី

ការស្តារ និងការអភិវឌ្ឍប្រទេសជាតិឡើងវិញ

យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី១ ទី២ និងទី៣៖

- ✓ កំណែទម្រង់រដ្ឋបាលសាធារណៈ/កំណែទម្រង់វិមជ្ឈការ
- ✓ កំណែទម្រង់សេដ្ឋកិច្ច និងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- ✓ កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
- ✓ កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ

# ១.សេចក្ដីផ្ដើម (ត)



អ្វីទៅជាវិមជ្ឈការ?



***វិមជ្ឈការក្នុងបរិបទទូទៅ៖***

❖ ជាដំណើរការមួយដែលសិទ្ធិអំណាច និងការទទួលខុសត្រូវនៃមុខងារសាធារណៈត្រូវបានផ្ទេរពីរដ្ឋាភិបាលកណ្ដាល ទៅរដ្ឋាភិបាលមូលដ្ឋាន សង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាលដទៃទៀត។

**វិមជ្ឈការក្នុងបរិបទនៃកម្ពុជា (ច្បាប់រៀបចំអង្គការ)៖**

❖ ជាដំណើរការដែលរាជរដ្ឋាភិបាលប្រគល់ឱ្យក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិនូវភាពជាម្ចាស់លើមុខងារ សិទ្ធិអំណាច និងធនធាន ដើម្បីឆ្លើយតបទៅនឹងសេចក្ដីត្រូវការរបស់មូលដ្ឋាន ហើយក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋមូលដ្ឋានលើបញ្ហាទាំងនេះ។

**វិសហមជ្ឈការ (ច្បាប់រៀបចំអង្គការ)៖**

❖ រាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័នធ្វើប្រតិភូកម្មមុខងារ សិទ្ធិអំណាច និងធនធានទៅអង្គភាពក្រោមបង្គាប់ ឬទៅក្រុមប្រឹក្សាប្រភេទណាមួយដើម្បីអនុវត្តក្នុងនាមរដ្ឋាភិបាល ឬក្រសួង ស្ថាប័ន។ អង្គភាព ឬក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័នលើការងារដែលបានប្រតិភូកម្មនោះ។

# ២. មូលហេតុនៃការធ្វើវិមជ្ឈការ






## ១. ពង្រឹង និងពង្រីកលទ្ធិប្រជាធិបតេយ្យ សេរី ពហុបក្ស៖

- ការបង្កើតក្រុមប្រឹក្សានៅរដ្ឋបាលថ្នាក់ក្រោមជាតិធ្វើជាតំណាងសំឡេង និងផលប្រយោជន៍ប្រជាពលរដ្ឋ តាមរយៈការបោះឆ្នោតដោយផ្ទាល់ និងដោយអសកល តាមគោលការណ៍ប្រជាធិបតេយ្យ សេរី ពហុបក្ស ។

## ២. លើកកម្ពស់ការផ្តល់សេវាសាធារណៈ និងអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន៖

- ផ្តល់លទ្ធភាពឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិដែលនៅកៀកប្រជាពលរដ្ឋ ផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន ឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ បានទាន់ពេលវេលា មានប្រសិទ្ធភាព និងគណនេយ្យភាព។

## ៣. កៀរគរធនធានមូលដ្ឋាន៖

- បង្កើននូវប្រភពធនធាននានាក្នុងសហគមន៍ ការប្រមូលផ្តុំនូវគំនិតផ្តួចផ្តើមដ៏សម្បូរណ៍បែបរបស់មូលដ្ឋាន ការកៀរគរកម្លាំងពលកម្មរបស់សហគមន៍ ការចូលរួម និងការផ្តល់មូលនិធិ។

# ៣. កិច្ចដំណើរការនៃកំណែទម្រង់វិមជ្ឈការ






**ឆ្នាំ ២០០១**

- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសងាត់


រាជរដ្ឋាភិបាលកម្ពុជា
ច្បាប់
ស្តីពី
ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
ច្បាប់
ស្តីពី
ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា
ឃុំ សង្កាត់
ការផ្សាយរបស់លេខាធិការដ្ឋាន គ.ជ.អ.ប
ខែ កុម្ភៈ ឆ្នាំ ២០០៩

**ឆ្នាំ២០០២ ការផ្លាស់ប្តូរជាប្រវត្តិសាស្រ្តប្រព័ន្ធគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់**

- ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ អាណត្តិទី១(២០០២-២០០៧)



- រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងថ្មីនៃឃុំ សង្កាត់
  - ✓ នីតិវិធីការងារ
  - ✓ ប្រព័ន្ធផែនការ
  - ✓ ការបង្កើតមូលនិធិឃុំ សង្កាត់
  - ✓ ប្រព័ន្ធហិរញ្ញវត្ថុ

លទ្ធផលវិជ្ជមាន៖
- លទ្ធផលនយោបាយ
- ការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន៖
  - ✓គម្រោងហេដ្ឋារចនាសម្ព័ន្ធ
  - ✓គម្រោងសេវាសង្គម
  - ✓គម្រោងប្រាក់ចំណូល
  - ✓គម្រោងការពារ&អភិរក្សធនធានធម្មជាតិ

# ៣. កិច្ចដំណើរការនៃកំណែទម្រង់វិមជ្ឈការ (ត)



| ឆ្នាំ ២០០៥ | ឆ្នាំ២០០៨ | ឆ្នាំ២០០៩ | ឆ្នាំ២០១០ |
|---|---|---|---|

**ឆ្នាំ ២០០៥**

- ក្របខ័ណ្ឌយុទ្ធសាស្ត្រ កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

ក្របខ័ណ្ឌយុទ្ធសាស្ត្រ
ស្តីពី
កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០០៥

**ឆ្នាំ២០០៨**

- វិសោធនកម្មរដ្ឋធម្មនុញ្ញ
- ច្បាប់រៀបចំអង្គការ


រាជរដ្ឋាភិបាលកម្ពុជា

ច្បាប់
ស្តីពី
ការគ្រប់គ្រងរដ្ឋបាល
រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
ច្បាប់
ស្តីពី
ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា
រាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង
ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ

ការផ្សាយរបស់ក្រសួងមហាផ្ទៃ
បោះពុម្ពលើកទី១ ចំនួន ១៧.០០០ក្បាល ខែសីហា ឆ្នាំ២០០៨

**ឆ្នាំ២០០៩**

- ការបោះឆ្នោតក្រុមប្រឹក្សា រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- រៀបចំរចនាសម្ព័ន្ធ និង ប្រព័ន្ធគ្រប់គ្រងឡើងវិញ



**ឆ្នាំ២០១០**

- កម្មវិធីជាតិរយៈពេល១០ឆ្នាំ សម្រាប់ធ្វើផែនទីបង្ហាញផ្លូវ


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

កម្មវិធីជាតិ
សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ
នៅថ្នាក់ក្រោមជាតិ
២០១០-២០១៩

ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១០

# ៣. កិច្ចដំណើរការនៃកំណែទម្រង់វិមជ្ឈការ(ត)

➢ កម្មវិធីជាតិត្រូវបានបែងចែកជា៣ដំណាក់កាលសម្រាប់ការអនុវត្ត៖

| ផអ៣ទី១ ៖ ២០១១-២០១៤ | ផអ៣ទី២ ៖ ២០១៥-២០១៧ | ផអ៣ទី៣៖ ២០១៨-២០២០ |
|---|---|---|
| ការកែសម្រួលរចនាសម្ព័ន្ធ និង ប្រព័ន្ធ និងនីតិវិធីថ្មីៗសម្រាប់ការគ្រប់គ្រង និងការអនុវត្តការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | ការផ្ទេរមុខងារ និងធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីកែលំអគុណភាពសេវា និងការអភិវឌ្ឍមូលដ្ឋាន | ការបន្តជំរុញ និងពង្រឹងការទទួលខុសត្រូវ និងស្វ័យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន |

➢ ផអ៣ទី១ និងទី២ត្រូវបានអនុវត្តចប់នៅដំណាច់ឆ្នាំ២០១៧។

➢ ផអ៣ទី៣ត្រូវបានរៀបចំ និងកំពុងអនុវត្តពីឆ្នាំ២០១៨ដល់ឆ្នាំ២០២០។

# ៤. សមិទ្ធផលនៃកំណែទម្រង់វិមជ្ឈការ



តើការធ្វើកំណែទម្រង់វិមជ្ឈការសម្រេចបានសមិទ្ធផលអ្វីខ្លះ?



- ✓ ការបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់(៤អាណត្តិ) និងក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (២អាណត្តិ) ធ្វើជាតំណាងប្រជាប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន បានប្រព្រឹត្តទៅដោយជោគជ័យ
- ✓ រចនាសម្ព័ន្ធ ប្រព័ន្ធ និងនីតិវិធីអនុវត្តការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត តាមគោលការណ៍នៃអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ
- ✓ ប្រព័ន្ធគ្រប់គ្រងបុគ្គលិក និងអភិវឌ្ឍធនធានមនុស្សតាមបែបវិមជ្ឈការនៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ និងដាក់ឱ្យដំណើរការ
- ✓ មុខងារចំនួន២០ត្រូវបានផ្ទេរជាបណ្តើរៗទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការប្រគល់ និងការធ្វើប្រតិភូកម្ម (មុខងារក្នុងវិស័យ បរិស្ថាន សង្គមកិច្ច អភិវឌ្ឍន៍ជនបទ ទេសចរណ៍ អប់រំ ឧស្សាហកម្ម រ៉ែ និងថាមពល)
- ✓ មុខងារផ្តល់សេវារដ្ឋបាលជាង២០០ប្រភេទត្រូវបានធ្វើប្រតិភូកម្មទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការិយាល័យច្រកចេញចូលតែមួយ (៥២ក្រុង ស្រុក)





# ៤. សមិទ្ធផលនៃកំណែទម្រង់វិមជ្ឈការ (ត)



ការធ្វើកំណែទម្រង់វិមជ្ឈការសម្រេចបានសមិទ្ធផលអ្វីខ្លះ?



✓ ថវិការផ្ទជាង២.០០០លានដុល្លាត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ សម្រាប់គ្រប់គ្រងចាត់ចែង និងប្រើប្រាស់ក្រោមឆន្ទានុសិទ្ធិរបស់ខ្លួន ក្នុងការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋានដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន៖

- ឃុំ សង្កាត់ជាង៦០៩លានដុល្លា (ឆ្នាំ២០០២-២០១៧)
- ក្រុង ស្រុកជាង១១១លានដុល្លា (២០១៣-២០១៧)
- រាជធានីខេត្តជាង១.២៨១លានដុល្លា(២០០៩-២០១៧)

✓ រដ្ឋបាលក្រោមជាតិបានប្រើប្រាស់ថវិកាទាំងនេះក្នុងការផ្តល់សេវាសាធារណៈ និងអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច និងផ្តល់សេវាសង្គម ប្រមាណ១.៨០០គម្រោងក្នុង១ឆ្នាំៗ

✓ ការិយាល័យប្រជាពលរដ្ឋត្រូវបានបង្កើតជាបណ្តើរៗនៅតាមរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីធ្វើជាយន្តការសម្រុះសម្រួល និងដោះស្រាយពាក្យបណ្តឹងតវ៉ាផ្នែករដ្ឋបាល

# ៥. ទិសដៅនៃកំណែទម្រង់វិមជ្ឈការ



តើកំណែទម្រង់វិមជ្ឈការមានទិសដៅអ្វីខ្លះ?



- បន្តពង្រឹងភាពជាម្ចាស់របស់រាជរដ្ឋាភិបាល ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការដឹកនាំ សម្របសម្រួល គ្រប់គ្រង និងអនុវត្តកំណែទម្រង់
- បន្តកែសម្រួលរចនាសម្ព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ កំណត់ឱ្យបានច្បាស់លាស់នូវតួនាទី និងការទទួលខុសត្រូវតាមប្រភេទ និងចរិតលក្ខណៈផ្សេងៗគ្នានៃរដ្ឋបាលថ្នាក់ក្រោមជាតិ
- បន្តលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងបុគ្គលិក និងការអភិវឌ្ឍធនធនមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការផ្តល់សិទ្ធិអំណាចកាន់តែច្រើនទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ
- បន្តផ្ទេរមុខងារក្នុងវិស័យអាទិភាពនានាទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយភ្ជាប់ជាមួយនឹងសិទ្ធិអំណាច ការទទួលខុសត្រូវ និងធនធានជាក់លាក់នានា
- បន្តពង្រឹង និងពង្រីកយន្តការផ្តល់សេវាតាមច្រកចេញចូលតែមួយទៅគ្រប់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ទាំងអស់ទូទាំងប្រទេស
- បន្តការធ្វើវិមជ្ឈការហិរញ្ញវត្ថុ ដើម្បីធានាដល់ការបង្កើនធនធានហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ រួមទាំងធនធានជាឆន្ទានុសិទ្ធិ  និងធនធានមានភ្ជាប់លក្ខខណ្ឌ។

# ៦.សេចក្តីសន្និដ្ឋាន



- កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការដែលបានអនុវត្តចាប់ពីឆ្នាំ២០០១មក បានបង្កើតនូវសមិទ្ធផលជាច្រើនពាក់ព័ន្ធទៅនឹងការកែសម្រួលឡើងវិញនូវរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងនីតិវិធីបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយឈរលើគោលការណ៍នៃរដ្ឋបាលឯកភាព ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ និងការចូលរួមរបស់ប្រជាពលរដ្ឋតាមលក្ខណៈប្រជាធិបតេយ្យ។
- សមិទ្ធផលជាង១ទសវត្សរ៍កន្លះមកនេះបង្ហាញឱ្យឃើញថា កំណែទម្រង់នេះបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការលើកកម្ពស់ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន ឆ្លើយតបទៅនឹងតម្រូវការ និងដោះស្រាយបញ្ហាប្រឈមនានានៅមូលដ្ឋាន ព្រមទាំងបានចូលរួមលើកស្ទួយជីវភាព និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព បរិយាប័ន្ន និងសមធម៌សង្គម។
- ជោគជ័យនៃកំណែទម្រង់គឺអាស្រ័យលើការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធទាំងអស់។ សូមអំពាវនាវ និងលើកទឹកចិត្តដល់យុវជនគ្រប់រូបចូលរួមកិច្ចដំណើរការកំណែទម្រង់ឱ្យបានកាន់តែសកម្ម និងខ្លាំងក្លាបន្ថែមទៀត។







# សូមអរគុណ!



